# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ៣២៣.ព្រទ-២០០០

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោក ប្រធានតុលាការនិងលោកព្រះរាជអជ្ញាខេត្តស្ទឹងត្រែង**

**លោកប្រធាន និងលោកព្រះរាជអាជ្ញាតុលាការខេត្តបន្ទាយមានជ័យ**

**សូមជ្រាប។**

**កម្មវត្ថុ:** ស្ដីពីការបញ្ជូនសម្រង់សាលក្រមព្រហ្មទណ្ឌទៅពន្ធនាគារ ។

**យោង:** លិខិតលេខ ៩៧០ស.ផ.ណ ចុះថ្ងៃទី០៥-១១-១៩៩៩ របស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធាន និងលោកព្រះរាជអាជ្ញអមតុលាការខេត្តស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យជ្រាបថា ដើម្បីឱ្យការរៀបចំនិងគ្រប់គ្រងទណ្ឌិត នៅក្នុងពន្ធនាគារឱ្យបានល្អ នៅពេលទណ្ឌិតត្រូវផុតកំណត់ទោសនោះ លោកត្រូវបញ្ជូនសម្រង់សាលក្រមព្រហ្មទណ្ឌទៅពន្ធនាគារខេត្តនីមួយៗឱ្យបានទៀងទាត់រាល់ពេលកាត់ក្ដីរួចជាស្ថាពរ ដើម្បីងាយស្រួលដល់មន្ត្រីពន្ធនាគារគ្រប់គ្រងទណ្ឌិតទាំងអស់នោះ ។

អាស្រ័យហេតុនេះ សូមលោកយកចិត្តទុកដាក់អនុវត្តចំពោះបញ្ហានេះដើម្បីជៀសវាងបញ្ហាដែលប៉ះពាល់ដល់សិទ្ធិមនុស្ស សិទ្ធិទណ្ឌិតផងដែរ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០០

**ជ.រដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

ចម្លងជូន
-តុលាការព្រះរាជអាជ្ញាគ្រប់ខេត្ត-ក្រុង
-ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
-ឯកសារ